# ព្រះវិហារចាស់នៅវត្តកណ្ដាល

វត្តកណ្ដាល ឬហៅថាវត្តសំរិទ្ធិជយារាម ស្ថាបនាឡើងនៅប្របតាមដងទន្លេធំ (ទន្លេមេគង្គ) ស្ថិតក្នុងឃុំកោះអណ្ដែត ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។ បើផ្អែកតាមចំណារនៅខាងមុខបល្ល័ង្កព្រះដីរ៍ឱ្យដឹងថា វត្តនេះមានឈ្មោះដើមហៅ "វត្តចុងកោះអណ្ដែត"។ បច្ចុប្បន្ននៅក្នុងបរិវេណវត្តមានព្រះវិហារពីរទន្ទឹមគ្នា កសាងជាប់លើខឿនតែមួយ (រូបលេខ១)។ ព្រះវិហារចាស់ស្ថិតនៅខាងត្បូង ជាព្រះវិហារដែលមានសសរឈើ និងគំនូរបុរាណគូរលើពិតានឈើយ៉ាងល្អវិចិត្រ ហើយអ្នកស្រាវជ្រាវយល់ថាព្រះវិហារនេះកសាងឡើងតាំងពីដើមសតវត្សរ៍ទី២០។ នៅក្នុងសម័យសង្គមរាស្ត្រនិយម ពុទ្ធបរិស័ទបានរួមគ្នាជួសជុលកែលម្អព្រះវិហារនេះម្ដង ហើយរហូតដល់ក្រោយសម័យកម្ពុជាប្រជាធិបតេយ្យ (ប៉ុល ពត) ព្រះវិហារនេះបានជួសជុលម្ដងទៀត។ ប៉ុន្តែក្រោយកសាងព្រះវិហារថ្មីរួចមក ព្រះវិហារចាស់ដែលមានអាយុកាលជាង១សតវត្សរ៍នេះ ហាក់ដូចជាពុំមានតួនាទីសំខាន់សម្រាប់រៀបចំពិធីបុណ្យទានតូចធំ ឬការគោរពបូជាផ្សេងៗដូចបុរាណកាលឡើយ។



រូបលេខ១ ព្រះវិហារចាស់នៅវត្តកណ្ដាល មើលពីជ្រុងអាគ្នេយ៍

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

## អត្ថបទ៖ ព្រះវិហារចាស់នៅវត្តកណ្ដាល

ព្រះវិហារចាស់ក្នុងវត្តកណ្ដាល សង់នៅលើខឿនកម្ពស់ត្រឹមចង្កេះ ទទឹងប្រហែល ៩ម៉ែត្រកន្លះ និងបណ្ដោយប្រហែល១៩ម៉ែត្រកន្លះ។ ព្រះវិហារនេះសង់អំពីឈើ ជញ្ជាំងរៀបឥដ្ឋ ជាប្រភេទព្រះវិហារជហ្វាបួន ដំបូលប្រក់ក្បឿងស្រកាលេញ។ ប៉ុន្តែបច្ចុប្បន្នព្រះវិហារខាងលើកំពុងស្ថិតក្នុងសភាពទ្រុឌទ្រោម ពុកផុយ ខូចទាំងទ្វារនិងបង្អួចដោយអន្ទើ។ (រូបលេខ២-៣)។ បើយោងតាមការសិក្សារបស់ *Danielle* និង *Dominique-Pieree Guéret* យល់ថាព្រះវិហារចាស់វត្តកណ្ដាលកសាងក្នុងឆ្នាំ១៩០៩ ហើយគំនូរលើជញ្ជាំងគូរនៅក្នុងឆ្នាំ១៩៦៤។[1] ប៉ុន្តែបើយោងតាមផ្ទាំងចារឹកមួយចារជាប់បល្ល័ង្កព្រះជីវ៍ ទីវត្តនេះកសាងតាំងពីពុទ្ធសករាជ២៤៣៨ (ឆ្នាំ១៨៩៥) ហើយព្រះវិហារកសាងក្នុងឆ្នាំ១៩០០។ មិនតែប៉ុណ្ណោះ នៅលើជញ្ជាំងខាងកើត មានចំណារមួយផ្ទាំងតូចទៀតដែលមានសេចក្ដីខ្ទីថា "បានរូស(រុះ)រើជញ្ជាំងចាស់ធ្វើជាថ្មីឡើងវិញពីឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥០៨"។ តាមសេចក្ដីនេះមានន័យថា ជញ្ជាំងព្រះវិហារសព្វថ្ងៃរុះរើរៀបថ្មីក្នុងឆ្នាំ១៩៦៥។



*រូបលេខ២-៣ ព្រះវិហារចាស់វត្តកណ្ដាល មើលពីជ្រុងពាយ័ព្យ និងមើលពីខាងលិច*

បច្ចុប្បន្ន គេមើលឃើញថាព្រះវិហារចាស់វត្តកណ្ដាល ជាព្រះវិហារមានលក្ខណៈពិសេសគួរឱ្យកត់សម្គាល់ ពោលគឺទាំងគ្រឹះ ជណ្ដើរ ជញ្ជាំង និងទ្វារ-បង្អួចទាំងអស់ពុំមានក្បាច់លម្អឡើយ។ នៅផ្នែកខាងមុខ និងខាងក្រោយមានជណ្ដើរនិងទ្វារម្ខាងពីរដូចគ្នា។ ចំណែកខាងចំហៀង គឺមានបង្អួចម្ខាង៧ ដូចគ្នាដែរ។ ប៉ុន្តែផ្នែកគ្រឿងបង្គុំដំបូល ហោជាង គល់ហោជាង រងស្បូវ សុទ្ធសឹងប្រកបដោយក្បាច់រនាយ៉ាងរស់រវើកក្រៃលែង។

---

[1] *Danielle* និង *Dominique-Pieree Guéret 2017: 109*

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

# *អត្ថបទ៖ ព្រះវិហារចាស់នៅវត្តកណ្ដាល*

*ចំពោះហោជាងខាងមុខរចនាពីឈើ លម្អដោយក្បាច់ភ្ញីភ្ញើងដែលមានរូបដើងពានទ្រទាន៥ដើមនៅចំកណ្ដាល និងមានស្លឹកឈើព័ទ្ធជាកម្រងពីក្រៅ។ នៅផ្នែកខាងលើ គេឆ្លាក់ក្បាលខាបមួយយ៉ាងធំមើលចំពីមុខ។ នៅគល់ហោជាង គេរចនាក្បាច់ធ្មេញក្របីនៅជួរខាងលើ និងក្បាច់ត្របកឈូកនៅជួរខាងក្រោម (រូបលេខ២៤)។ ចំណែកឯនៅលើហោជាងខាងលិច ក៏ធ្វើពីឈើដែរ តែហោជាងនេះរចនាជាក្បាច់ភ្ញីទេស ដែលមានដើមប្រទាក់គ្នាយ៉ាងល្អវិសេស។ នៅផ្នែកកណ្ដាលគេឆ្លាក់ជារូបដើងពានទ្រគម្ពីរ(?) និងឆ័ត្ររួតមួយនៅខាងលើ ព្រមទាំងឆ័ត្ររួតមួយគូទៀតអមសងខាង (រូបលេខ២៥)។ ទន្ទឹមនឹងនេះផ្ទៃហោជាងទាំងពីរសុទ្ធតែដាំកញ្ចក់លម្អយ៉ាងភ្លឺផ្លេកដូចគ្នា។*



*រូបលេខ២៤ ក្បាច់លម្អលើផ្ទៃហោជាងខាងកើត*



*រូបលេខ២៥ ក្បាច់លម្អលើផ្ទៃហោជាងខាងលិច*

*ដោយឡែកក្រៅពីក្បាច់រចនាលម្អលើហោជាងដូចរៀបរាប់ខាងលើ នៅលើរងស្សូវនៃព្រះវិហារចាស់ក្នុងវត្តកណ្ដាល ក៏ឃើញមានក្បាច់លម្អឆ្លាក់ពីឈើគួរឱ្យចាប់អារម្មណ៍។ រងស្សូវព្រះវិហារនេះ លម្អដោយក្បាច់កញ្ចាំងក្នុងទម្រង់ស្លឹកពោធិបញ្ឆិតទាំងអស់ ដែលនៅខាងចុងសន្ទឹកមានសណ្ឋានដូចក្បាច់ភ្ញីភ្ញើង។ ប៉ុន្តែអ្វីដែលកាន់តែពិសេស គឺនៅលើរងស្សូវចំហៀងទាំងសងខាងនៃចុងដំបូលខាងលើបំផុត គេឆ្លាក់ផ្នែកកណ្ដាលនៃខ្សែក្បាច់ជារូបរាហូ។ ចំណែកឯនៅខាងចុងខ្សែក្បាច់ទាំងសងខាង គេឆ្លាក់រូបហនុមានប្រយុទ្ធនឹងយក្ស (រូបលេខ២៦-៨)។ ការឆ្លាក់លម្អលើរងស្សូវបែបនេះ គេឃើញស្រដៀងនឹងរងស្សូវព្រះវិហារចាស់វត្តរកាកណ្ដាល នៅខេត្តក្រចេះ។ មិនតែប៉ុណ្ណោះ នៅលើសន្ទឹកក្បាច់រងស្សូវនីមួយៗសុទ្ធតែមានដាំកញ្ចក់ភ្លឺផ្លេកដូចការដាំកញ្ចក់លម្អលើហោជាងដែរ។*

*អត្ថបទដោយ៖ ហៀន សុវណ្ណមរកត*





រូបលេខ៦-៨ ក្បាច់លម្អ និងការឆ្លាក់រូបផ្សេងៗនៅលើរងស្បូវ

ចំណែកខាងក្នុងព្រះវិហារ មានសសរឈើ៣២ដើម សង់ឡើងជាបីល្វែង ពោលគឺល្វែងគ្រឹះនៅកណ្ដាល និងរបៀងសងខាង (រូបលេខ៩)។ នៅចុងខាងលិចល្វែងគ្រឹះ មានបល្ល័ង្កខ្ពស់មួយយ៉ាងល្អវិចិត្រតម្កល់ព្រះបដិមាព្រះជីវ័ធំ។ ខឿនបល្ល័ង្ក មានគំនូរពាក់ព័ន្ធរឿងពុទ្ធប្រវត្តិ និងចំណារសារបានវត្តចារនៅខាងមុខ ដែលនាំឱ្យដឹងថាព្រះជីវ័សព្វថ្ងៃកសាងឡើងវិញក្នុងឆ្នាំ១៩៨១។ ចំណុចពិសេសនៃបល្ល័ង្កនេះ គឺនៅលើតួបល្ល័ង្ករចនាជាក្បាច់ភ្ញី និងរូបផ្សេងៗតាមរបៀប "គំនូរបុក" ដែលឃើញនិយមក្នុងសិល្បៈខ្មែរតាំងពីដើមសតវត្សរ៍ទី២០ (រូបលេខ១០)។[2] ចំពោះពិតានព្រះវិហារនេះ គឺជាពិតានឈើដែលរៀបចំឡើងតែលើចន្លោះល្វែងគ្រឹះប៉ុណ្ណោះ។ គំនូរនៃពិតាន ជាប្រភេទគំនូរបុរាណដែលអ្នកខ្លះយល់ថាគូរទន្ទឹមពេលគ្នានឹងការសង់ព្រះវិហារ។ ប្រធានបទសំខាន់ៗគូរលើពិតាន គឺរូបព្រះអាទិត្យ ព្រះចន្ទ្រ និងទេពនិករនានាលើអាកាស (រូបលេខ១១)។[3]



រូបលេខ៩ ល្វែងខាងក្នុងវិហារ




រូបលេខ១០-១១ គំនូរផ្សេងៗលើពិតាន

[2] សូមអានបន្ថែម៖ ព្រាប ចាន់ម៉ារ៉ា ២០០៩-២០១០: ៣៨-៤១

[3] សូមអានបន្ថែម៖ សាន ផល្លា ២០០៥-២០០៦: ៨៧-៨៩

អត្ថបទដោយ៖ ហឿន សុវណ្ណមរកត

## *អត្ថបទ៖ ព្រះវិហារចាស់នៅវត្តកណ្ដាល*

គំនូរលើជញ្ជាំងជុំវិញ គូររៀបរាប់អំពីរឿងពុទ្ធប្រវត្តិ ដោយផ្ដើមពីត្រង់ព្រះអង្គទ្រង់ប្រសូតលើជញ្ជាំងខាងត្បូង ចុងខាងកើត រួចសាច់រឿងបន្តទៅជញ្ជាំងខាងលិចដែលមានផ្ទាំងសំខាន់គឺព្រះអង្គផ្ចាញ់មារលើជញ្ជាំងចំខាងក្រោយបល្ល័ង្កព្រះជីវ៍ រហូតមកបញ្ចប់ត្រង់ព្រះអង្គបរិនិព្វាន និងចែកព្រះបរមសារីរិកធាតុលើជញ្ជាំងខាងកើតដូចព្រះវិហារផ្សេងៗដែរ។ បើផ្អែកតាមចំណារមួយនៅលើជញ្ជាំងខាងកើត បញ្ជាក់ច្បាស់ថា "ចាប់ផ្ដើមកសាងគំនូរនៅខែទុតិយាសាឍ ឆ្នាំកុរ បញ្ចស័ក ព.ស.២៥២៦ ត្រូវនឹងថ្ងៃទី១ ខែសីហា ឆ្នាំ១៩៨៣។ ក្នុងការកសាងនេះ ពុទ្ធបរិស័ទខ្លះមានសទ្ធាចេញប្រាក់ជួលជាងគូរតាមផ្ទាំងមួយៗ [តាម]គ្រួសារមួយៗ។ ពុទ្ធបរិស័ទខ្លះមានសទ្ធាឧបត្ថម្ភជាងទទួលវេនធ្វើម្ហូបអាហារ ជរាបហើយស្រេចនៅថ្ងៃ១៥កើត ខែផល្គុណ ឆ្នាំជដែល ត្រូវនឹងថ្ងៃទី១៦ ខែមីនា ឆ្នាំ ១៩៨៤"។ ដូច្នេះគំនូរលើជញ្ជាំងជុំវិញព្រះវិហារ ពុំមែនសាងឡើងក្នុងឆ្នាំ១៩៦៤ ដូច *Danielle* និង *Dominique-Pieree Guéret* យល់ឡើយ ដ្បិតម្យ៉ាងទៀតជញ្ជាំងព្រះវិហារនេះបានរុះរើសាងថ្មីក្នុងឆ្នាំ១៩៦៥។

បើតាមសង្កេត ចំណុចពិសេសនៃគំនូរពុទ្ធប្រវត្តិក្នុងព្រះវិហារខាងលើ គឺវិចិត្រករគូរបញ្ចូលតួអង្គអតីតព្រះមហាក្សត្រ និងទិដ្ឋភាពសង្គមខ្មែរខ្លះ ក្នុងឈុតមួយចំនួនដូចការនិយមាក្នុងសម័យសង្គមរាស្ត្រនិយម។ ឈុតព្រះអង្គទ្រង់ប្រសូត្រ គេគូរពួកទេពនិករនៅផ្នែកម្ខាង ឯផ្នែកខាងទៀតប្រហែលគេគូរបញ្ជាក់ព្រះវត្តមានក្សត្រ និងវត្តមានអ្នកនគរផ្សេងៗ ដែលក្នុងនោះវិចិត្រករហាក់មានចេតនាចង់គូរបង្ហាញតួអង្គ ***ព្រះបរមរតនកោដ្ឋ*** ទ្រង់គ្រឿងព្រះពស្ត្រក្បិនពណ៌លឿង និងព្រះភូសាកុតកត្រង់ តែពុំមានព្រះសុពណ៌បាទឡើយ (រូបលេខ១២)។ រីឯគំនូរត្រង់ឈុតព្រះអង្គបិណ្ឌបាត្រនៅនគរកបិលភស្ដុ ក្រៅពីបង្ហាញឱ្យឃើញពីព្រះអង្គនិមន្តនាំមុខភិក្ខុរាប់រយអង្គ ដោយព្រះវត្តមានព្រះសុទ្ធោទន៍យាងមកថ្វាយបង្គំ វិចិត្រករបានគូរបញ្ចូលសំណង់ខ្លះមានលក្ខណៈស្មើរដូចព្រះបរមរាជវាំងក្រុងចតុមុខ។ មិនតែប៉ុណ្ណោះ អ្វីដែលគួរឱ្យចាប់អារម្មណ៍ គឺការគូរបង្ហាញទង់ជាតិនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា នៅខាងចុងនៃជួរភិក្ខុទាំងឡាយ (រូបលេខ១៣)។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



រូបលេខ១២ កាលព្រះអង្គទ្រង់ប្រសូត



រូបលេខ១៣ ព្រះអង្គបិណ្ឌបាត្រនៅក្រុងកបិលភស្តុ

ដូច្នេះតាមរយៈការរៀបរាប់ដោយសង្ខេបខាងលើ គេអាចយល់បានថា ព្រះវិហារចាស់នៅវត្តកណ្ដាល គឺជាសំណង់បេតិកភណ្ឌមានអាយុកាលជាង១០០ឆ្នាំ កសាងឡើងប្រកបដោយទេពកោសល្យ និងទឹកដៃសិល្បៈយ៉ាងល្អឆើត ដែលធ្លាប់មានការជួសជុលថែរក្សារាប់តំណមក។ ការរចនាផ្សេងៗ រាប់ទាំងជហ្វា នាគចែង ហោជាង រងស្បូវ គំនូរបុរាណលើពិតាន និងបល័ង្កព្រះជីវ៍ ក៏ជាផ្នែកយ៉ាងសំខាន់នៃសិល្បៈខ្មែរដើមសតវត្សរ៍ទី២០។ ប៉ុន្តែចំពោះជញ្ជាំងព្រះវិហារ គឺជាជញ្ជាំងថ្មីរៀបឥដ្ឋកាលពីឆ្នាំ១៩៦៥ ហើយគំនូរនានាលើជញ្ជាំង ជាការរៀបចំគូរក្នុងឆ្នាំ១៩៨៣ រហូតបញ្ចប់ក្នុងឆ្នាំ១៩៨២ ដែលខុសពីការយល់របស់ Danielle និង Dominique-Pieree Guéret ថាជញ្ជាំង និងគំនូរសាងឆ្នាំ១៩៦២ឡើយ។ មិនតែប៉ុណ្ណោះ ចំណុចពិសេសនៃគំនូរលើជញ្ជាំងព្រះវិហារខាងលើ គឺវិចិត្រករបានបញ្ចេញសេរីភាពសិល្បៈ បង្ហាញទម្រង់ព្រះភ័ក្ត្រអតីតព្រះមហាក្សត្រ នៅក្នុងរបបដឹកនាំដែលពុំគាំទ្ររាជានិយម។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

# ឯកសារយោង

ព្រាប ចាន់ម៉ារ៉ា

២០០៩-២០១០, "គំនូរបុក", *កម្រងអត្ថបទក្នុងបណ្ដាញព័ត៌មានវប្បធម៌ខ្មែរ, លេខ២៥.* ទំ.៣៨-៤១, Friends of Khmer Culture, ភ្នំពេញ

សាន ផល្លា

២០០៥-២០០៦, "ព្រះអាទិត្យនិងព្រះចន្ទនៅក្នុងសង្គមខ្មែរ", *កម្រងអត្ថបទក្នុងបណ្ដាញព័ត៌មានវប្បធម៌ខ្មែរ, លេខ១.* ទំ.៨៧-៨៩, Friends of Khmer Culture, ភ្នំពេញ

Daniell Guéret & Dominique-Pierre Guéret

2017, *The Khmer Pagoda,* Kam editions

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត